**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៦៨)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៦ ៣៦៦នាក់ នៃរោងចក្រ សហគ្រាសទាំង២២ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាសទាំង២២ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ពុធ ៩រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែកញ្ញា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១

បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍
ចំនួន ២២ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 3 |
| 1 | ក្រុមហ៊ុន ខេភីអិនអិល ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុន អូខូត អ៊ិនធើណេសិនណល(ខេមបូឌា)ហ្គាម៉ិន ឯ.ក | ស្វាយរៀង |
| 3 | ក្រុមហ៊ុន យូលី អ៊ិនធើណេសិនណល(ខេមបូឌា)ហ្គាមេន | ស្វាយរៀង |
| ខ. វិស័យទេសចរណ៍ | | 19 |
| 4 | ក្រុមហ៊ុន ឡឺ ប្រេស៊ីដង់អូតែល-កូបេ | ភ្នំពេញ |
| 5 | សណ្ឋាគារ ហ្គឺឌិន ស៊ីធី ហូថេល | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ផ្លាហ្សា ព្រីមៀ ឡូញ (ខេមបូឌា) សាខាសៀមរាប | សៀមរាប |
| 7 | សណ្ឋាគារ លីនរតនះអង្គរ | សៀមរាប |
| 8 | ក្រុមហ៊ុន ហ្វ៊ូដ អេន បេវើរិច សឺលូសិន | សៀមរាប |
| 9 | ក្រុមហ៊ុន អានឡុង អេហ្សេត អ៊ិវេសមេន | សៀមរាប |
| 10 | ក្រុមហ៊ុន អេប៉ិច ខេមបូឌា ត្រាវ៉ែល ស៊ែរវីស | សៀមរាប |
| 11 | ក្រុមហ៊ុន ឡូទុស ប្លង្គ រីសត | សៀមរាប |
| 12 | ភោជនីយដ្ឋាន មីស វុង | សៀមរាប |
| 13 | ភោជនីយដ្ឋានចាន់រីទ្រី | សៀមរាប |
| 14 | ភោជនីយដ្ឋានសុខៈវីវើ | សៀមរាប |
| 15 | សណ្ឋាគារ វីចេនស៊ីអង្គរ | សៀមរាប |
| 16 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 18 | ក្រុមហ៊ុន ហ្គោលដេន ទ្រី ព្រីនស៍ ហូថែល និងស្ប៉ា | សៀមរាប |
| 19 | សណ្ឋាគារ អូរៀនថល ជេ7 | សៀមរាប |
| 20 | ក្រុមហ៊ុន ខ្មែរអង្គរហូថែលកូអិលធីឌី | សៀមរាប |
| 21 | សណ្ឋាគារ អង្គរ | សៀមរាប |
| 22 | ក្រុមហ៊ុន អេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |